# របាយការណ៍ប្រចាំឆ្នាំ
# ៣១ ធ្នូ ២០២៣

## អ អិម អេ (ខេមបូឌា) ម.ក

## R M A (CAMBODIA) PLC.



អ អិម អេ (ខេមបូឌា)

ផ្ទះលេខ ២៧ ផ្លូវ១៣៤ ប្រអប់សំបុត្រ ៥៥ សង្កាត់មិត្តភាព ខណ្ឌ៧មករា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទលេខ (៨៥៥) ២៣ ៨៨៨ ០០០ ទូរសារ (៨៥៥) ២៣ ៤២៦ ៧៥២

www.cambodia.rmagroup.net

## ចក្ខុវិស័យ

ទស្សនៈវិស័យរបស់យើងគឺដើម្បីក្លាយទៅជាដៃគូដែលទុកចិត្តបំផុត និងយូរអង្វែងសម្រាប់ការអភិវឌ្ឍន៍ និងវិបុលភាពនៅកម្ពុជា៖

| ធនធានមនុស្ស | អតិថិជន | អ្នកផ្គត់ផ្គង់ |
|---|---|---|
| ជាមនុស្សដែលមានការលើកទឹកចិត្តខ្ពស់ និងមានការចូលរួម និងមានភាពងប់ងល់ការទទួលខុសត្រូវ ភាពច្នៃប្រឌិត និងភាពច្នៃប្រឌិតក្នុងការស្វែងរកដំណោះស្រាយល្អបំផុតចំពោះបញ្ហារបស់មនុស្សដើម្បីធ្វើអោយជីវិតប្រសើរឡើង។ | អតិថិជនមានភាពសប្បាយរីករាយដែលត្រូវបានបំរើសេវាកម្មដោយបុគ្គលដែលទទួលបានការកោតសរសើរពីក្រុមហ៊ុន RMAC ជាមួយនឹងអ្នកជំនាញ គុណភាពផលិតផល ដំណោះស្រាយ និងសេវាកម្មអតិថិជនដែលគ្មានគូរប្រៀប។ | បណ្តាញអ្នកផ្គត់ផ្គង់អតិថិជនដែលឈ្នះដោយការគោរពគ្នា និងមានមហិច្ឆិតាចែករំលែកដើម្បីធ្វើឱ្យជីវិតកាន់តែប្រសើរឡើង។ |

## បេសកកម្ម និងតម្លៃ

អ អិម អេ (ខេមបូឌា) ម.ក ("**RMAC**" ឬ "**ក្រុមហ៊ុន**") ជាក្រុមហ៊ុនឈានមុខគេក្នុងវិស័យផ្គត់ផ្គង់គ្រឿងយន្តនៅក្នុងប្រទេសកម្ពុជា។

RMAC បានចូលមកក្នុងទីផ្សារប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩២ ក្នុងនាមជាផ្តល់ដំណោះស្រាយខាងផ្នែកពាណិជ្ជកម្ម និងក្រៅពាណិជ្ជកម្ម ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ថាមពល និងដឹកជញ្ជូន។

ក្រុមហ៊ុនបានរីកចំរើនយ៉ាងឆាប់រហ័សទន្ទឹមគ្នានិងការអភិវឌ្ឍរបស់ប្រទេសកម្ពុជា ហើយបានពង្រីកខ្លួនក្នុងវិស័យ យានយន្ត កសិកម្ម សំណង់ ឧបករណ៍លើកដាក់ ឧបករណ៍សម្អាត និង សេវាកម្មបន្ទាប់ពីផ្នែកលក់។

RMAC បានទទួលកេរ្តិ៍ឈ្មោះក្នុងនាមជាអ្នកចែកចាយយានយន្តនិងគ្រឿងចក្រលំដាប់ពិភពលោក ដោយរួមបញ្ចូលម៉ាក Ford (តាំងពីឆ្នាំ ១៩៩៧), TCM (តាំងពីឆ្នាំ២០០៨), JCB (តាំងពីឆ្នាំ២០១០), FUSO (តាំងពីឆ្នាំ២០១០), John Deere (តាំងពីឆ្នាំ២០១១), Jaguar Land Rover (តាំងពីឆ្នាំ២០១៣), MS Pallet (តាំងពីឆ្នាំ២០១៣), Megger & Sebar (តាំងពីឆ្នាំ២០១៣), GenieGrips (តាំងពីឆ្នាំ២០១៧), Hako (តាំងពីឆ្នាំ២០១៨), PowerBoss (តាំងពីឆ្នាំ២០១៨) , AJAX (តាំងពីឆ្នាំ២០១៩), Piaggio (តាំងពីឆ្នាំ២០២០), Changan (តាំងពីឆ្នាំ២០២២), Haulotte (តាំងពីឆ្នាំ២០២២), សេវាកម្មក្រោយការលក់ Mercedes-Benz (តាំងពីឆ្នាំ២០២៣) និង គ្រឿងបន្លាស់រថយន្ត (ថ្នាំលាបរថយន្ត និង អាគុយ) (តាំងពីឆ្នាំ២០២៣).

សម្រាប់អតិថិជនរបស់យើងនៅក្នុងទីផ្សារ RMACគឺជាដៃគូរយូរអង្វែងជាជាងអ្នកផ្គត់ផ្គង់យូរអង្វែង។ យើងបានវិនិយោគក្នុងការផ្តល់ការងារ និងការគាំទ្រទៅលើគុណភាពនៃផលិតផលរបស់យើងជាមួយនឹងការប្តេជ្ញាចិត្តមិនផ្លាស់ប្តូរដើម្បីផ្តល់សេវាកម្មបន្ទាប់ពីការលក់ជានិរន្តរ៍។



ភាពច្នៃប្រឌិត

RMAC ទទួលបានភាពជោគជ័យ ទៅលើការផ្តល់ដំណោះស្រាយច្នៃប្រឌិតដែលត្រូវតាមតម្រូវការរបស់អតិថិជនយ៉ាងជាក់លាក់។



ភាពសុចរិត

RMAC តែងតែខិតខំប្រឹងប្រែងយ៉ាងល្អបំផុតសម្រាប់អតិថិនរបស់ខ្លួន។ អ្វីក៏ដោយដែលក្រុមហ៊ុនបានធ្វើគឺធ្វើដោយភាពត្រឹមត្រូវនិងយកចិត្តទុកដាក់។



ភាពអត់ធ្មត់

RMAC នៅតែបន្តការវិនិយោគដ៏យូរអង្វែងនៅក្នុងអាជីវកម្មរបស់ខ្លួន ភាពជាដៃគូជាមួយអតិថិជន និងភាពស្ថិតស្ថេរនៃផលិតផល និងដំណោះស្រាយផងដែរ។

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាពាន់រៀល) | ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ១.០៩៣.៥១១.៧១០ | ៨៨៩.២៩៥.២៣២ | ៦០៨.១៥៩.៥៣០ |
| បំណុលសរុប | ៥៨៦.៦០៩.៧៤៦ | ៤៥១.៣៩២.៤៣៣ | ៣២២.២៤០.៨២០ |
| មូលធនក្រុមហ៊ុនសរុប | ៥០៦.៩០១.៩៦៤ | ៤៣៧.៩០២.៧៩៩ | ២៨៥.៩១៨.៧១០ |
| ប្រាក់ចំណេញ(ខាត) / (គិតជាពាន់រៀល) | ២០២៣ | ២០២២ | ២០២១ |
| ចំណូលសរុប | ១.៨០០.៣៦២.០៩៤ | ២.២០៣.២៥៣.៤៥៣ | ១.៦២៦.៥៤០.០២៤ |
| ប្រាក់ចំណេញមុនបង់ពន្ធ(ខាត)/ | ១៣៩.៤២០.៣០០ | ២៩៦.០៥៨.៩១៣ | ១៨៦.៨២២.៩៩៣ |
| ប្រាក់ចំណេញ(ខាត)/ក្រោយបង់ពន្ធ | ១១៣.៧២៣.១៣៣ | ២៤៣.៥៦៥.៥៣០ | ១៥៧.៣៥៨.០៧៨ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ១០៩.៨៧៦.៣៦៦ | ២៤៧.៦៦៨.៨២៣ | ១៥៨.៨៥៧.៨៥៣ |
| អនុបាតហិរញ្ញវត្ថុ | ២០២៣ | ២០២២ | ២០២១ |
| អនុបាតសាធនភាព | ១,២ | ១,០ | ១,១ |
| អនុបាតចរន្ត (Current Ratio) | ២,៥ | ២,០ | ២,០ |
| អនុបាតចរន្តលឿន (Quick Ratio) | ០,៦ | ០,៧ | ១,០ |
| អនុបាតផលចំណេញ | ២០២៣ | ២០២២ | ២០២១ |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម | ១១,១% | ៣៣,១% | ៣០,៩% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម | ២៣,៣% | ៦៨,៤% | ៦៦,៨% |
| គម្លាតចំណេញដុល (Gross Profit Margin) | ១៧,៤% | ១៩,០% | ១៥,៩% |
| គម្លាតចំណេញ (Profit Margin) | ៦,១% | ១១,២% | ៩,៨% |
| អនុបាតលទ្ធភាពសងការប្រាក់ | ៥,៧ | ២៤,១ | ២១,៨ |

## ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប









## ប្រាក់ចំណូល និងចំណូលសុទ្ធ ( គិតជាពាន់រៀល )



# សមាជិកក្រុមប្រឹក្សាភិបាល



Wiedmann Christian | ងន សាំង | Kevin Whitcraft | Tom Whitcraft | Vichit Ith

លោក Kevin Whitcraft
ប្រធានក្រុមប្រឹក្សាភិបាល

លោក ងន សាំង
អភិបាលប្រតិបត្តិ

លោក Tom Whitcraft
អភិបាលមិនប្រតិបត្តិ

លោក Wiedmann Christian
អភិបាលមិនប្រតិបត្តិ

លោក Ith Vichit
អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

វិនិយោគិនជាទីគោរព

ក្នុងរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំមុនៗ ខ្ញុំបាទបានជម្រាបជូនអំពីរបាយការណ៍សង្ខេប ស្តីពីលទ្ធផលប្រតិបត្តិការហិរញ្ញវត្ថុរបស់ **ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក** (**"តទៅហៅកាត់ថា "RMAC"**)។

ក្រឡេកទៅឆ្នាំ២០២៣ និងត្រីមាសចុងក្រោយ វាពិតជាមានសារៈសំខាន់ណាស់ក្នុងការពិចារណាលើស្ថានភាពប្រទេសកម្ពុជានៅក្នុងបរិបទក្នុងស្រុក តំបន់ និងពិភពលោក។ ប្រទេសកម្ពុជាបានឆ្លងកាត់ការផ្លាស់ប្តូរការគ្រប់គ្រងប្រកបដោយសន្តិវិធីទៅកាន់មេដឹកនាំកម្ពុជាជំនាន់ក្រោយ ដែលបានមកជាមួយនឹងយុទ្ធសាស្ត្រវិជ្ជមានសម្រាប់ការបន្តដំណើររបស់កម្ពុជា។ ការបន្តគោលនយោបាយសេដ្ឋកិច្ចទីផ្សារសេរី សេដ្ឋកិច្ចពហុបរិយប័ណ្ណ និងបរិយាកាសស្វាគមន៍យ៉ាងបើកចំហសម្រាប់អ្នកវិនិយោគក្នុងស្រុក និងអន្តរជាតិបានបង្កើនទំនុកចិត្តនាពេលអនាគត។ ការកើនឡើងនៃសកម្មភាពសេដ្ឋកិច្ច និងទស្សនវិស័យវិជ្ជមាននៅចុងត្រីមាសចុងក្រោយនៃឆ្នាំ ២០២៣ បានបង្ហាញថាយុទ្ធសាស្ត្រនេះកំពុងដំណើរការល្អ។

RMAC បន្តជាតួអង្គសំខាន់នៅក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជាក្នុងនាមជាផ្គត់ផ្គង់យានយន្ត បរិក្ខារកសិកម្ម និងបរិក្ខារឧស្សាហកម្ម។ តាមទស្សនៈរបស់ក្រុមហ៊ុនតាំងពីការចាប់ផ្តើមបង្កើតនៅក្នុងប្រទេសកម្ពុជា យើងតែមានចក្ខុវិស័យយូរអង្វែង និងបន្តស្វែងរកឱកាសក្នុងការលើកកម្ពស់វិស័យអាជីវកម្មរបស់យើងនៅក្នុងប្រទេសកម្ពុជា។ នៅឆ្នាំ ២០២៣ ទោះបីជាអាជីវកម្មរបស់យើងមានការធ្លាក់ចុះធៀបនឹងឆ្នាំ ២០២២ក៏ដោយ RMAC នៅតែបន្តទៅមុខ និងវិនិយោគសម្រាប់ពេលអនាគត។

ការណ៍នេះបណ្តាលឱ្យមានការវិនិយោគដើមទុនជាច្រើននៅក្នុងបរិក្ខារ (ទាំងរូបវន្ត និងធនធានមនុស្ស) ដើម្បីគាំទ្រសេវាកម្មថែទាំយានយន្ត និងការអនុវត្តរយៈពេលវែងនៃផលិតផលដែលបានលក់តាមតម្រូវការ និងគួរត្រូវបានរំពឹងទុកដោយអតិថិជនរបស់យើង។

ចំណុចសំខាន់នៃការវិនិយោគនេះរួមមាន

- ការបើកអគារបង្ហាញលក់ ផ្តល់សេវាកម្ម និងគ្រឿងបន្លាស់រថយន្ត Ford នៅជ្រោយចង្វារ
- ការបើកមជ្ឈមណ្ឌលសម្រាប់ឧបករណ៍ធុនធ្ងន់ (JCB) ឧបករណ៍កសិកម្ម (John Deere) និងម៉ាកឧស្សាហកម្មផ្សេងទៀតនៅលើផ្លូវជាតិលេខ៦
- ការទិញយកកន្លែងតាំងបង្ហាញផ្នែកលក់ និងសេវាកម្មរបស់ Mercedes Benz នៅមហាវិថីសម្តេចហ៊ុន សែន
- ការវិនិយោគដ៏សំខាន់នៅក្នុងប្រព័ន្ធប្រតិបត្តិការផែនការធនធានសហគ្រាសថ្មី ("ERP") សម្រាប់អាជីវកម្មដើម្បីធានាបាននូវការគ្រប់គ្រងដ៏រឹងមាំ និងការចូលរួមកាន់តែរឹងមាំជាមួយបុគ្គលពាក់ព័ន្ធ។
- ការអភិវឌ្ឍន៍ផ្នែកទំនាក់ទំនងអតិថិជនក្នុងការហៅទូរសព្ទចូល២៤ ម៉ោង ដើម្បីរក្សាទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយអតិថិជនរបស់យើង និងធានាបាននូវជំនួយបច្ចេកទេសភ្លាមៗ។

ការពង្រីកភាពជាដៃគូជាមួយក្រុមហ៊ុនហិរញ្ញវត្ថុធំៗ ធនាគារ និងគណនីសំខាន់ៗបានបន្តពេញមួយឆ្នាំ។ ការវិនិយោគរបស់ RMAC នៅក្នុង BSP Finance Cambodia បានបង្ហាញពីផលចំណេញនៃភាគលាភយ៉ាងរឹងមាំសម្រាប់ក្រុមហ៊ុន។

វិស័យឧស្សាហកម្មរថយន្តកម្ពុជាឆ្នាំ២០២៣ គឺជាឆ្នាំដ៏លំបាកជាមួយនឹងការធ្លាក់ចុះនៃការលក់នូវត្រីមាសបន្ទាប់ ដែលបណ្តាលឱ្យមានការធ្លាក់ចុះពីមួយឆ្នាំទៅមួយឆ្នាំមានចំនួន-២៨% បើធៀបនឹងការលក់នៅក្នុងឆ្នាំ ២០២២។ ប្រសិនបើយើងបង្រួមការវិភាគទៅលើទីផ្សាររថយន្តថ្មី ការធ្លាក់ចុះត្រូវបានកំណត់ត្រឹមចំនួន -១៣%។ នៅក្នុងគ្រាដ៏លំបាកនេះ ការលក់របស់ RMAC បានធ្លាក់ចុះចំនួន -១៨.៣% បើប្រៀបធៀបទៅនឹងឆ្នាំ ២០២២ (ជាឆ្នាំដែល RMAC លក់រថយន្តថ្មីបំផុត)។ ឧស្សាហកម្មទាំងអស់បានជួបការលំបាកដូចៗគ្នា ប្រសិនបើមិនធ្ងន់ធ្ងរជាងនេះក្នុងអំឡុងឆ្នាំ ២០២៣។ បញ្ហាប្រឈមនេះនាំឱ្យសារពើភ័ណ្ឌមានការកើនឡើងខ្ពស់ជាងការរំពឹងទុក និងជាលទ្ធផលដែលបណ្តាលអាត្រាការប្រាក់ខ្ពស់ជាងមុនក្នុងមួយឆ្នាំនាពេលថ្មីៗនេះដែលជាប្រវត្តិសាស្ត្រ។

ទោះបីជាមានការផ្លាស់ប្តូរបរិបទសង្គមក៏ដោយ RMACបានបន្តបើកដំណើរការរថយន្តថ្មី និងពង្រឹងសកម្មភាពរបស់ខ្លួនជាមួយនឹងផលិតផលសំខាន់ៗដូចខាងក្រោម៖

- រថយន្ត Pick-up truck ម៉ាក់ Ford Ranger ស៊េរីឆ្នាំ ២០២៣
- ការពង្រីកខ្លួនរបស់រថយន្ត Changan ដោយបន្ថែមរថយន្តម៉ាក UNI-K និងម៉ាក់ CS55

ក្រុមហ៊ុន និង អ្នកគ្រប់គ្រងរបស់យើងបានពង្រឹងទំនាក់ទំនងដ៏រឹងមាំជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងជាមួយសាកលវិទ្យាល័យនានា ដើម្បីបណ្តុះបណ្តាល និងទាក់ទាញយុវជនដែលមានទេពកោសល្យ។ ការបន្តគាំទ្រដល់ការផ្តល់កម្មវិធីសិក្សាសម្រាប់ការអប់រំអ្នកបច្ចេកទេសដែលមានជំនាញចាំបាច់ក្នុងការថែទាំ ជួសជុល និងដំណើរការយានយន្ត និងឧបករណ៍ដែលទំនើប និងទាន់សម័យ។

ក្រុមហ៊ុន RMAC បានបន្តរក្សាភាពឈានមុខគេក្នុងវិស័យយានយន្តនៅប្រទេសកម្ពុជា, ជាពិសេសនៅក្នុងទីផ្សាររថយន្តមិនប្រណិត ជាមួយរថយន្តម៉ាក Ford និងម៉ាក Chang An, ទីផ្សាររថយន្តប្រណិតដូចជាម៉ូដែល Land Rover, មិនត្រឹមតែប៉ុណ្ណោះក្នុងនាមជាអ្នកចូលរួមចំណែកដ៏សំខាន់ នៅក្នុង វិស័យកសិឧស្សាហកម្ម តាមរយៈការនាំចូល និងចែកចាយ ផលិតផលគ្រឿងចក្រម៉ាកចនឌា រថយន្តដឹកទំនិញម៉ូដែល Mitsubishi Fuso គ្រឿងចក្រធុនធ្ងន់ម៉ូដែលJCB ម៉ូតូកង់បីម៉ូដែល Piaggio និងឧបករណ៍លើកដាក់សម្ភារៈម៉ូដែល TCM។

RMAC បានបន្តតួនាទីរបស់ខ្លួនជាអ្នកឧបត្ថម្ភចម្បងដល់ក្រុមហ៊ុន RMA Automotive Cambodia (RMAAC) ដែលជាក្រុមហ៊ុនតម្លើងរថយន្តដំបូងគេនៅក្នុងប្រទេសកម្ពុជានៅឆ្នាំ២០២២។ យើងពិតជាមានមោទនភាពក្នុងការប្រកាសថានៅឆ្នាំ ២០២៣ រថយន្ត Ford ច្រើនជាង ២.០០០ ម៉ូដែល (Ford Ranger Wildtrak និង Ford Everest) ដែលបានលក់ដោយ RMAC ត្រូវបានតម្លើងដោយ RMAAC ។

យុទ្ធសាស្ត្ររបស់ RMAC ក្នុងការចែកចាយម៉ាកល្បីៗជាសាកលក្នុងប្រទេសកម្ពុជាបានបង្ហាញពីការពង្រឹងទំនាក់ទំនងជាមួយនឹងក្រុមហ៊ុនផលិតឧបករណ៍ដើមរបស់យើង។ យើងជាដៃគូនៃជម្រើសដ៏ល្អក្នុងប្រទេសកម្ពុជាសម្រាប់ម៉ាកយីហោអន្តរជាតិ ជាមួយនឹងឱកាសកាន់តែច្រើនដែលត្រូវបានវិនិយោគក្នុងពេលអនាគត។

RMAC មានមោទនភាពដែលបានទទួលលិខិតថ្លែងអំណរគុណពីរាជរដ្ឋាភិបាលកម្ពុជាក្នុងរយៈពេលពីរឆ្នាំជាប់ៗគ្នា ដោយទទួលស្គាល់ក្នុងចំនោមជាក្រុមហ៊ុនបង់ពន្ធខ្ពស់បំផុតរបស់ប្រទេស។ ក្នុងនាមជាសាជីវកម្មធំជាងគេមួយរបស់កម្ពុជា យើងមានមោទនភាពចំពោះការរួមចំណែកដ៏សំខាន់របស់យើងចំពោះសង្គមកម្ពុជា។ យើងក៏ប្តេជ្ញាបន្តគាំទ្រចំពោះអាទិភាពរបស់រដ្ឋាភិបាលកម្ពុជា តាមរយៈការអនុវត្តអាជីវកម្ម និងការវិនិយោគប្រកបដោយការទទួលខុសត្រូវ។

RMAC ត្រូវបានទទួលស្គាល់ថាជាក្រុមហ៊ុនដ៏ឆ្នើមមួយផ្នែកភស្តុភារ(Logistics) និងការអនុលោមតាមការនាំចូល។ នៅឆ្នាំ២០២៣ RMAC បានទទួលនូវវិញ្ញាបនបត្រនៃគុណសម្បត្តិពីអង្គការគយពិភពលោក ដែលជាការបង្ហាញឱ្យឃើញពីការខិតខំប្រឹងប្រែងរបស់ក្រុមហ៊ុនក្នុងការសម្រេចបាននូវកាតព្វកិច្ចពន្ធ និងកាតព្វកិច្ចពេញលេញ។

ជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់ RMAC ក្នុងការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងប្រជាជនផងដែរនោះ RMAC បានធ្វើការជ្រើសរើសបុគ្គលិកថ្មីជាង១៥០នាក់នៅក្នុងឆ្នាំ២០២៣ និងបានរួមចំណែកក្នុងការផ្តល់ឱកាសនូវការបណ្តុះបណ្តាលជាច្រើនដល់បុគ្គលិកដែលមានស្រាប់របស់យើង។ RMAC ទទួលបានពានរង្វាន់ ពីរ(០២)ឆ្នាំជាប់ៗគ្នា ដែលជាពានរង្វាន់ "ក្រុមហ៊ុនល្អបំផុតដើម្បីធ្វើការនៅអាស៊ីសម្រាប់ឆ្នាំ២០២៣" ដោយ HR Asia ដែលបង្ហាញពីលទ្ធផលដ៏ល្អដែលទទួលបានពីទស្សនវិស័យនៃការចូលរួមរបស់បុគ្គលិក។

RMAC ខិតខំជំរុញគំនិតផ្តួចផ្តើមស្តីពីទំនួលខុសត្រូវសង្គមរបស់សាជីវកម្ម(CSR) ដែលមានឥទ្ធិពល។ នៅឆ្នាំ២០២៣ RMAC បានទទួលពានរង្វាន់ CSR Excellence Award លើវិស័យអប់រំពីសភាពាណិជ្ជកម្មអាមេរិក។ RMAC បានចូលរួមយ៉ាងសកម្មក្នុងខែឧសភា ឆ្នាំ២០២៣ ក្នុងការជួសជុលសាលាបឋមសិក្សាក្រពុំឈូក ក្នុងខេត្តតាកែវ ដើម្បីឱ្យបរិយាកាសសិក្សារបស់កុមារកាន់តែមានភាពប្រសើរឡើង។

ជាកិច្ចបញ្ចប់ ខ្ញុំចង់កត់សម្គាល់នូវសេចក្តីសោមនស្សរបស់ខ្ញុំចំពោះការខិតខំប្រឹងប្រែង និងការប្រឹក្សាយោបល់ដែលផ្តល់ដោយក្រុមប្រឹក្សាភិបាលរបស់ RMAC និងសូមអរគុណដល់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ RMAC ទាំងអស់ សម្រាប់ការពង្រីកអាជីវកម្មបន្ថែមទៀត និងតែងតែយកចិត្តទុកដាក់ចំពោះកិច្ចការងារ ដើម្បីបម្រើដល់អតិថិជនរបស់យើង និងប្រតិបត្តិការនៃការលក់ផលិតផលរបស់ក្រុមហ៊ុន។ មានតែចំណង់ចំណូលចិត្ត និងជំនាញនោះទេ ដែលធ្វើឱ្យយើងជោគជ័យ ក្នុងការបង្កើនការបេជ្ញាចិត្តរបស់RMA ចំពោះព្រះរាជាណាចក្រកម្ពុជា។

យើងកំពុងទន្ទឹងរង់ចាំនៅឆ្នាំ២០២៤ដើម្បីពង្រីកអាជីវកម្មរបស់យើងបន្ថែមទៅមុនទៀតតាមរបៀបនិរន្តរភាព។

**លោក** Kevin Whitcraft

**ប្រធានក្រុមប្រឹក្សាភិបាល**

កាលបរិច្ឆេទ៖ ១៩ មេសា ២០២៤

# សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ

វិនិយោគិនជាទីគោរព

តាមការឆ្លុះបញ្ចាំងក្នុងឆ្នាំ២០២៣ ខ្ញុំចង់បង្ហាញនូវគន្លឹះខ្លះៗអំពីការប្រតិបត្តិរបស់ក្រុមហ៊ុនយើងខ្ញុំស្របពេលជាមួយនឹងសេដ្ឋកិច្ចប្រទេសកម្ពុជាកំពុងតែជួបការលំបាក និងឧស្សាហកម្មរថយន្ត។

ឧស្សាហកម្មរថយន្តនៅកម្ពុជាបានប្រឈមមុខនឹងការលំបាកយ៉ាងខ្លាំងនៅឆ្នាំ២០២៣ ដែលធ្វើឱ្យការលក់មានការធ្លាក់ចុះចំនួន-២៨% បើប្រៀបធៀបទៅនឹងឆ្នាំមុន ដោយសារភាពមិនចិតថេរនៃសេដ្ឋកិច្ចអត្រាការប្រាក់ធ្លាក់ចុះ និងការប្រែប្រួលនៃចំណង់ចំណូលចិត្តរបស់អ្នកប្រើប្រាស់ បានបង្ហាញពីបញ្ហាប្រឈមយ៉ាងខ្លាំង។ ទោះបីជាមានឧបសគ្គទាំងនេះក៏ដោយ ខ្ញុំមានមោទនភាពក្នុងការប្រកាសថាក្រុមហ៊ុនរបស់យើងបានផ្តល់នូវលទ្ធផលហិរញ្ញវត្ថុដ៏គួរឱ្យសរសើរ ដែលជាសក្ខីភាពដល់អតិថិជនដែលតែងតែគាំទ្រដល់យើងតាំងពីដើមរហូតមក និងការវិវត្តន៍របស់យើងឱ្យទាន់តាមស្ថានភាពសង្គម។

លទ្ធផលហិរញ្ញវត្ថុរបស់យើងនៅឆ្នាំនេះ ត្រូវបានគាំទ្រដោយគំនិតផ្តួចផ្តើមលើយុទ្ធសាស្រ្តជាច្រើន។ យើងបានពង្រីកវិសាលភាពរបស់យើងតាមរយៈការបើកដំណើរការរថយន្ត Ford និង Changan ដែលជាម៉ូដែលថ្មីដ៏គួរជាទីចាប់អារម្មណ៍ ព្រមទាំងបើកសម្ពោធសេវាកម្មក្រោយការលក់នៃរថយន្ត Mercedes-Benz និងបើកដំណើរការផ្នែកគ្រឿងបន្លាស់បន្សំរថយន្ត ដើម្បីសម្រួលដល់ការប្រតិបត្តិបច្ចុប្បន្ន។ យើងបានបើកផ្នែកទំនាក់ទំនងអតិថិជន(Call-center) ប្រកបដោយបច្ចេកទេសច្នៃប្រឌិត និងទំនើប ដើម្បីបង្កើនភាពងាយស្រួលក្នុងការទំនាក់ទំនងជាមួយអតិថិជនរបស់ក្រុមហ៊ុនរបស់យើង។ កិច្ចខិតខំប្រឹងប្រែងទាំងនេះមិនត្រឹមតែបានជួយយើង ក្នុងការស្វែងរកការជួបបញ្ហាប្រឈមនៃឆ្នាំ២០២៣ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរក្សាជំហរយើងឱ្យបានល្អសម្រាប់ការរីកចម្រើននាពេលអនាគតផងដែរ។

ទោះបីជាយ៉ាងណាក៏ដោយ យើងនៅតែពុំមានសេចក្តីសោមនស្ស។ យើងទទួលស្គាល់ថាឧស្សាហកម្មនេះបន្តវិវត្តន៍ក្នុងល្បឿនយ៉ាងលឿន ហើយយើងត្រូវតែបន្តនាំមកនូវនាវានុវត្តថ្មី និងសម្របខ្លួនដើម្បីរក្សាការប្រកួតប្រជែងរបស់យើង។ នៅក្នុងឆ្នាំ២០២៤ យើងបានរៀបចំគម្រោងវិនិយោគបន្ថែមទៅលើសម្ភារៈបរិក្ខារ និងមជ្ឈមណ្ឌលសេវាកម្មថ្មីៗ ដើម្បីពង្រឹងសមត្ថភាពឌីជីថលរបស់យើង និងស្វែងរកឱកាសអាជីវកម្មថ្មីៗដើម្បីបង្កើនបទពិសោធន៍អតិថិជន និងបង្កើតតម្លៃសម្រាប់ម្ចាស់ភាគហ៊ុនរបស់យើង។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបុគ្គលិកទាំងអស់សម្រាប់ការលះបង់ និងការខិតខំប្រឹងប្រែងនាពេលកន្លងមក ហើយសូមថ្លែងអំណរគុណដល់ម្ចាស់ភាគហ៊ុនទាំងអស់របស់យើងសម្រាប់ការជឿទុកចិត្ត និងការគាំទ្ររបស់អ្នក។ យើងខ្ញុំប្តេជ្ញាចិត្ត ក្នុងការតបស្នងនូវគុណតម្លៃរយៈពេលវែង និងការផ្តល់ជូនសហគមន៍របស់យើងនូវភាពជោគជ័យ និងទន្ទឹងរង់ចាំក្នុងការស្វែងរកដំណើរឆ្ពោះទៅមុខជាមួយគ្នា។

សូមអរគុណចំពោះការបន្តគាំទ្ររបស់អ្នកទាំងអស់គ្នាគន្លងមក។

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អ រិម អេ (ខេមបូឌា) ម.ក
RMA (CAMBODIA) PLC.
KINGDOM OF CAMBODIA

**លោក ខន សាំង**

**នាយកប្រតិបត្តិក្រុមហ៊ុន អ រិម អេ (ខេមបូឌា)**

កាលបរិច្ឆេទ៖ ១៩ មេសា ២០២៤

# មាតិកា


ចក្ខុវិស័យ ........................................................................................................................ ២

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ........................................................................................................ ៣

ក្រាបស្តីអំពីស្ថានភាពហិរញ្ញវត្ថុសង្ខេប .................................................................................... ៤

សមាជិកក្រុមប្រឹក្សាភិបាល ...................................................................................................... ៦

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ............................................................................... ៧

សេចក្តីថ្លែងរបស់នាយកប្រតិបត្តិ ........................................................................................... ១១

ផ្នែកទី១. ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ ...................................................................... ១៥

ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ ......................................................................................... ១៥

ខ. សកម្មភាពអាជីវកម្ម ........................................................................................................ ១៥

គ. រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនបោះផ្សាយ ................................................................................... ១៦

ឃ. ព្រឹត្តិការណ៍សំខាន់ៗរបស់ក្រុមហ៊ុនបោះផ្សាយ ......................................................................... ១៦

ង. ស្ថានភាពទីផ្សារ ............................................................................................................. ២២

ច. សកម្មភាពប្រកួតប្រជែង .................................................................................................... ២២

ឆ. គ្រោងការណ៍អនាគត ....................................................................................................... ២២

ជ. កត្តាហានិភ័យ ............................................................................................................... ២៣

ផ្នែកទី២. ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ................................................................... ២៤

ក. លទ្ធផលប្រតិបត្តិការធុរកិច្ច រាប់បញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ................................................. ២៤

ខ. រចនាសម្ព័ន្ធប្រាក់ចំណូល .................................................................................................. ២៤

ផ្នែកទី៣. ព័ត៌មានស្តីអំពីអភិបាលកិច្ចរបស់ក្រុមហ៊ុន ................................................................. ២៥

ផ្នែកទី៤. ព័ត៌មានស្តីអំពីការលក់ដមូលបត្រ និងម្ចាស់ភាគហ៊ុន .................................................... ២៨

ក. ព័ត៌មានស្តីពីមូលបត្រ ....................................................................................................... ២៨

ខ. តម្លៃមូលបត្រ និងបរិមាណនៃការលក់ ..................................................................................... ២៩

គ. ការគ្រប់គ្រងម្ចាស់ភាគហ៊ុន (៣០% ឬលើសពី៣០%)..........២៩
ផ្នែកទី៥ - របាយការណ៍សវនកម្មផ្ទៃក្នុងស្តីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន..........៣០
ផ្នែកទី៦ - របាយការណ៍ហិរញ្ញវត្ថុត្រួតពិនិត្យដោយសវនករផ្ទៃក្នុង..........៣២
ផ្នែកទី៧ - ព័ត៌មានស្តីពីប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍..........៣៣
ផ្នែកទី៨ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង..........៣៤
ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ..........៣៤
ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ..........៣៥
គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល..........៣៥
ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ..........៣៦
ង. ផលប៉ះពាល់នៃអតិផរណា..........៣៦
ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល..........៣៦
ឆ. ព្រឹត្តិការណ៍សំខាន់ៗ..........៣៦
ហត្ថលេខាអភិបាលរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ..........៣៧
ឧបសម្ព័ន្ធ៖ របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ (បានភ្ជាប់ជាមួយរបាយការណ៍ប្រចាំឆ្នាំ)

## ផ្នែកទី១.- ព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយ

### ក. ព័ត៌មានអំពីក្រុមហ៊ុនបោះផ្សាយ

| | |
|---|---|
| **ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាខ្មែរ** | អ អិម អេ (ខេមបូឌា) ម.ក |
| **ឈ្មោះរបស់ក្រុមហ៊ុនបោះផ្សាយជាភាសាឡាតាំង** | RMA (CAMBODIA) PLC |
| **លេខកូដស្តង់ដារ** | KH2000121A44 |
| **អាសយដ្ឋាន** | ផ្ទះលេខ ២៧ E1 ផ្លូវ ១៣៤ សង្កាត់មិត្តភាព ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| **លេខទូរស័ព្ទ** | +៨៥៥ (0) ២៣ ៨៨៣ ៨៨៨ / ១២ ៨៦៧ ៦៩៧ |
| **លេខទូរសារ** | +៨៥៥ (0) ២៣ ៩២៦ ៧៥២ |
| **គេហទំព័រ** | www.cambodia.rmagroup.net |
| **អ៊ីម៉ែល** | saing.ngorn@rmagroup.net |
| **លេខចុះបញ្ជីក្រុមហ៊ុន** | ០០០០១១២១ ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០០២ |
| **លេខចុះបញ្ជីឯកសារផ្តល់ព័ត៌មាន** | ០០៦៨/២០ គ.ម.ក សសរ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២០ |
| **ឈ្មោះអ្នកតំណាងរបស់ក្រុមហ៊ុនបោះផ្សាយ** | លោក ងន សាំង |
| **លេខាធិការក្រុមហ៊ុន** | លោក មាស សុវណ្ណ (អ៊ីមែល៖ sovan.meas@rmagroup.net) |

### ខ. សកម្មភាពអាជីវកម្ម

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនចែកចាយរថយន្ត គ្រឿងចក្រកសិកម្ម និងគ្រឿងបន្លាស់ធន់ធ្ងន់នៅក្នុងប្រទេសកម្ពុជា ហើយក៏ជាក្រុមហ៊ុនផ្តល់ការធានា និងសេវាកម្មក្រោយការលក់សម្រាប់ម៉ាកល្បីៗលំដាប់ពិភពលោករួមមានដូចជា Ford, TCM, JCB, FUSO, John Deere, Jaguar Land Rover, MS Pallet, Megger & Sebar, GenieGrips, Hako, PowerBoss, AJAX, Piaggio, Changan, Haulotte, សេវាកម្មក្រោយការលក់ Mercedes-Benz និង គ្រឿងបន្លាស់រថយន្ត (ថ្នាំលាបរថយន្ត និង អាគុយ) ដែលបានបន្ថែមនៅក្នុងឆ្នាំ២០២៣។

ប៉ុន្មានឆ្នាំកន្លងមកនេះ ក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះជាក្រុមហ៊ុនផ្តល់សេវាកម្មនាំចូលរថយន្ត និង ផ្តល់ដំណោះស្រាយលើសេវាកម្មផ្សេងៗដែលទាក់ទងនឹងគ្រឿងផ្គត់ផ្គង់ និងការតម្លើងដំបូងគេបង្អស់។ ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនមេរបស់ RMA Group ដែលមានទីស្នាក់ការកណ្តាលប្រតិបត្តិប្រចាំតំបន់នៅទីក្រុងបាងកក ប្រទេសថៃ។

## គ. រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនបោះផ្សាយ

| ល.រ | ឈ្មោះក្រុមហ៊ុន | ប្រភេទនៃទំនាក់ទំនង | ភាគរយនៃការកាន់ភាគហ៊ុន | ស្វូលនៃអាជីវកម្ម | ថ្ងៃចុះបញ្ជីក្រុមហ៊ុន | អាសយដ្ឋាន |
|---|---|---|---|---|---|---|
| ១ | Clipper Holding Ltd | ក្រុមហ៊ុនហូលឌីង នៃ ក្រុមហ៊ុន អ អិម អេ គ្រុប | ៩៩,៩% | ក្រុមហ៊ុនកាន់កាប់ | ០៥ តុលា ២០០៧ | 31/F., Tower Two Times Square 1 Matheson Street, Causeway Bay HONG KONG |

## ឃ. ព្រឹត្តិការណ៍សំខាន់ៗរបស់ក្រុមហ៊ុនបោះផ្សាយ

### គម្រប់ខួបរោងចក្រ និងព្រឹត្តិការណ៍ទីដៅអាជីព



### គម្រប់ខួប១ឆ្នាំនៃរោងចក្រដំឡើងរថយន្តម៉ាក FORD

នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ ត្រូវជាមួយនឹងថ្ងៃគម្រប់ខួបលើកទីមួយ នៃការសម្ពោធរោងចក្រ Ford Assembly Plant នេះ ក្រុមហ៊ុន RMAC បានរៀបចំប្រគល់រថយន្តសង្គ្រោះបន្ទាន់ចំនួន ២ គ្រឿង ដល់កាកបាទក្រហមកម្ពុជា ដោយ បានអញ្ជើញសារព័ត៌មានសាខាខេត្តពោធិ៍សាត់ចូលរួមក្នុងពិធីនេះដែលធ្វើឡើងនៅ MB state-of-the - art facilities ស្ថិតនៅលើផ្លូវមហាវិថី ហ៊ុន សែន។



### ការបរិច្ចាគ

នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ ក្រុមហ៊ុន RMAC បានរៀបចំពីធីប្រគល់រថយន្តសង្គ្រោះបន្ទាន់ ចំនួន២គ្រឿង ដល់កាកបាទក្រហមកម្ពុជា។

## ទិសដៅអាជីព




នៅថ្ងៃទី ១៨ ខែកក្កដា ថ្មីៗនេះ ក្រុមហ៊ុន RMAC បាន សហការជាមួយសាកលវិទ្យាល័យន័រតុន (Norton University) រៀបចំសិក្ខាសាលាតម្រង់ទិសអាជីព ដោយមានចំណងជើងថា "ការតម្រង់ទិសអាជីព"។ សិក្ខាសាលានេះ ធ្វើឡើងដោយមានវត្តមានរបស់វាគ្មិនកិត្តិយសគឺៈ លោក Grant Honeymen ដែលជាប្រធានគ្រប់គ្រងទូទៅផ្នែកធនធានមនុស្ស និង រដ្ឋបាល និងលោក សុខ សុទ្ធារ៉ា ជាប្រធានគ្រប់គ្រងទូទៅនៃ ត្រាក់ទ័រ ចនឌារ ខេមបូឌា នៅ ក្រុមហ៊ុន អ អិម អេ (ខេមបូឌា)។

## ការសម្ពោធអាគារថ្មី




### ការបើកសម្ពោធអគារតាំងបង្ហាញរថយន្តម៉ាក
### FORD CHROY CHANGVAR

ពិធីនេះ ត្រូវបានអញ្ជើញចូលរួមពីថ្នាក់ដឹកនាំនៃក្រុមហ៊ុន Ford Motor Company ក្រុមហ៊ុន RMA Group ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) និងភ្ញៀវកិត្តិយសចំនួន ១០០ នាក់។

## ព្រឹត្តិការណ៍តាំងពិព័រណ៍




### Land Rover ចូលរួមជាមួយ MOC ក្នុងពិព័រណ៍ នាំចូល-នាំចេញ

កម្ពុជាធ្វើជាម្ចាស់ផ្ទះរួមគ្នាជាមួយ MOC ពិព័រណ៍ផលិតផលកម្ពុជា និងពិព័រណ៍ទំនិញនាំចូល នាំចេញលើកទី១៦។

## ការសម្ពោធផលិតផល




### ការសម្ពោធជាផ្លូវការនូវ Changan UNI-K

RMAC សម្ពោធការមកដល់នៃ Changan UNI-K ថ្មីនៅ ដី ព្រមៀ សេនធ័រ សែនសុខ។ ព្រឹត្តិការនេះបានស្វាគមន៍ភ្ញៀវចំនួន១,៥០០នាក់។




### សម្ពោធជាផ្លូវការ CHANGAN CS55+ S'23

RMAC បានសម្ពោធការមកដល់ជាផ្លូវការនៃ New Changan CS55 PLUS Series 2023 នៅ ដី ព្រមៀ សេធ័រ សែនសុខ ដែលមានភ្ញៀវចូលរួមសរុប ១៩២០ នាក់។ ពិធីសម្ពោធនេះ ធ្វើឡើងក្រោមវត្តមានដ៏មានកិត្តិយសរបស់ ឯកឧត្តម ចេន សេងហៀង អគ្គនាយករង នៃវិទ្យាស្ថានស្តង់ដារកម្ពុជា។




### ការសម្ពោធជាផ្លូវការនូវរថយន្តម៉ាក RANGER RAPTOR ជំនាន់ថ្មី (ម៉ាស៊ីនប្រេងម៉ាស៊ូត)

Ford ខេមបូឌា បានរៀបចំកម្មវិធីសម្ពោធជាផ្លូវការ រថយន្តម៉ាក Ranger Raptor 2.0L Bi-Turbo (Diesel) នៅ ដី ព្រមៀ សេនធ័រ សែនសុខ ដែលមានភ្ញៀវចូលរួមជាង ៣,០០០ នាក់។

## ទំនាក់ទំនងសាធារណៈ







RMAC បានចូលរួមជាអ្នកពិភាក្សានៅក្នុងកម្មវិធី Breakfast Talk ស្តីពីទស្សនវិស័យវិស័យយានយន្តសម្រាប់ឆ្នាំ ២០២៣ ដែលរៀបចំដោយសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា និងសហព័ន្ធឧស្សាហកម្មយានយន្តកម្ពុជា។ តាមទស្សនៈវិស័យឯកជន លោក ងន សាំង នាយកប្រតិបត្តិក្រុមហ៊ុន អ អិម អេ (ខេមបូឌា) និងលោក Roberto Da Silva នាយកប្រតិបត្តិក្រុមហ៊ុន HGB Group បានចែករំលែកទស្សនៈរបស់ពួកគាត់លើនិន្នាការនៃទីផ្សាររថយន្តថ្មី រថយន្តអគ្គិសនី និងការវិនិយោគដែលមានសក្តានុពលនៅក្នុង វិស័យឧស្សាហកម្មផលិតរថយន្ត។ លោក ឈឿន មករា ជាប្រធានគម្រោង នៃ RMAC និងជាប្រធានគណៈកម្មាធិការយានយន្ត EuroCham។

## ពានរង្វាន់



World Customs Organization
Organisation mondiale des douanes

CERTIFICATE OF MERIT

On the occasion of the International Customs Day,
the World Customs Organization awards this certificate to

RMA (CAMBODIA) Co., Ltd.

representing

Trade Facilitation Affairs in Cambodia

for rendering exceptional service to the international Customs community

Kunio Mikuriya
Secretary General

### វិញ្ញាបនបត្រ

វិញ្ញាបនបត្រនៃ Merit ពី World Custom Organization ដែលមានក្រុមហ៊ុនអាជីវកម្មល្អបំផុតចំនួន ១០ ដែលបានចូលរួមក្នុងការបង្កើនប្រសិទ្ធភាព នៃការសម្របសម្រួលពាណិជ្ជកម្ម ការពង្រឹងការអនុលោមតាម និងការបំពេញកាតព្វកិច្ចពន្ធ និងកាតព្វកិច្ច។




### អ អិម អេ ទទួលបានពានរង្វាន់ AMCHAM CSR ឧត្តមភាពនៅក្នុងវិស័យអប់រំ

ស្ពាបនាមជ្ឈដ្ឋានគ្រឹះសម្រាប់មនុស្សជំនាន់ក្រោយ។




## អ អិម អេ ទទួលបានពានរង្វាន់ ក្រុមហ៊ុនឈានមុខក្នុងវិស័យការងារនៅក្នុងអាស៊ី

រយៈពេលពីរឆ្នាំជាប់គ្នាហើយដែល RMA បានឈ្នះពានរង្វាន់ដ៏មានកិត្យានុភាព ដែលបញ្ជាក់ពីភាពប្តេជ្ញាចិត្តចំពោះបុគ្គលិករបស់យើង។



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ជូនចំពោះ
លោក-លោកស្រីនាយក
សហគ្រាស អ អិម អេ (ខេមបូឌា) ម.ក
R M A (CAMBODIA) PLC.
លេខអត្តសញ្ញាណកម្មសារពើពន្ធ L001-100050115

ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរដោយស្មោះអស់ពីដួងចិត្តជូនចំពោះ លោក-លោកស្រីនាយកសហគ្រាស ដែលបានចូលរួមចំណែកក្នុងការបំពេញកាតព្វកិច្ចបង់ពន្ធដារផ្ទៃក្នុងជូនរដ្ឋ និងជាសហគ្រាសជាប់ចំណាត់ថ្នាក់លេខ ១៩ ក្នុងចំណោមសហគ្រាសដែលបានបង់ពន្ធច្រើនជាងគេ និងទទួលបានអនុលោមភាពសារពើពន្ធប្រភេទមាស ក្នុងឆ្នាំ២០២២។

ការបំពេញកាតព្វកិច្ចបង់ពន្ធរបស់សហគ្រាសលោក-លោកស្រី គឺជាការចូលរួមចំណែកដែលមិនអាចខ្វះបានពីវិស័យឯកជនដែលជាដៃគូដ៏សំខាន់របស់រដ្ឋ និងជាកម្លាំងចលករសម្រាប់ការអភិវឌ្ឍនិងរីកលូតលាស់នៃសេដ្ឋកិច្ច និងសង្គមជាតិកម្ពុជា។

សូមជូនពរលោក-លោកស្រីនាយក ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់និងបុគ្គលិកទាំងអស់ទទួលបានជោគជ័យរាល់កិច្ចអាជីវកម្ម និងសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃពុធ ១០ កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣

ហ៊ុន សែន

## លិខិតសរសើរ

ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក បានទទួលលិខិតថ្លែងអំណរគុណពីនាយករដ្ឋមន្ត្រី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលបានបំពេញកាតព្វបង់ពន្ធលើប្រាក់ចំណូលសាជីវកម្មជូនរដ្ឋាភិបាល។ អ អិម អេ បានជាប់ចំណាត់ថ្នាក់លេខ១៩ ក្នុងចំណោមក្រុមហ៊ុនដែលបង់ពន្ធខ្ពស់បំផុតក្នុងប្រទេសកម្ពុជា សម្រាប់ឆ្នាំ ២០២២។ អ អិម អេ (ខេមបូឌា) ទទួលបានឋានៈមាសក្នុងការអនុលោមតាមពន្ធ។

# ព្រឹត្តិការណ៍ CSR



## អ អិម អេ បានបរិច្ចាគជូនដល់សិស្សដែលជួបការលំបាកនៅភូមិប្រាសាទថ្មីកម្ពុជា

RMAC បានបរិច្ចាគកង់ និងសម្ភារៈសិក្សា ដល់សិស្សានុសិស្សដែលជួបការលំបាក នៃសាលាសៀកថ្មីកម្ពុជា ដែលជាសាលារបស់ NGO ដែលមានទីតាំងនៅក្នុងខេត្តសៀមរាប។



គណៈគ្រប់គ្រងក្រុមហ៊ុន RMAC គ្រោងបើកម៉ូតូកង់បី Piaggio ក្នុងរាជធានីភ្នំពេញ ដើម្បីប្រមូលថវិកាបរិច្ចាគ ជូនដល់សិស្សពិការ នៃវិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី ក្នុងឱកាសទិវានៃក្ដីស្រឡាញ់អន្តរជាតិ។




### ការអប់រំ

ក្រុមហ៊ុន RMAC បានចូលរួមក្នុងកម្មវិធី TVET ឆ្នាំ ២០២៣ (ការអប់រំបច្ចេកទេស និងវិជ្ជារៈ) ដែលបានដាក់តាំងបង្ហាញផ្នែកអាជីវកម្មរបស់ RMAC ជាច្រើន រួមមាន រថយន្ត ហេដ្ឋារចនាសម្ព័ន្ធ និងឧបករណ៍ឧស្សាហកម្ម។



### ការឧបត្ថម្ភ

Ford ខេមបូឌា បានឧបត្ថម្ភកម្មវិធីដំណើរកំសាន្តរបស់អត្តពលិកនៅក្នុងព្រឹត្តិការណ៍ ស៊ីហ្គេម (the SEAGAME Athlete Trip) នៅខេត្តព្រះសីហនុ។ ពីធីនេះធ្វើឡើងក្រោមវត្តមាន លោកជំទាវបណ្ឌិត កុយ ពិសី រដ្ឋលេខាធិការក្រសួងទេសចរណ៍ និងជាអគ្គលេខាធិការគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា។

## ការដាក់ដំណើរការផ្នែកនីមួយៗ




### ការសម្ពោធជាផ្លូវការ Mercedes-Benz AFS

ការចាប់ផ្ដើមយុទ្ធនាការរបស់ ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ក្នុងនាមជាអ្នកផ្ដល់សេវាសម្រាប់ម៉ាក Mercedes-Benz នៅក្នុងប្រទេសកម្ពុជា ដែលមានការអនុញ្ញាត ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣។




## ការសម្ពោធជាផ្លូវការ នៃផ្នែកទំនាក់ទំនងអតិថិជន ( Call Center ) នៃក្រុមហ៊ុន អ អិម អេ

ផ្នែកទំនាក់ទំនងអតិថិជន (Call Center) ត្រូវបានបង្កើតឡើងដើម្បីបម្រើ និងពង្រឹងទំនាក់ទំនងជាមួយអតិថិជនពីគ្រប់ផ្នែក/ការផ្តល់សេវាកម្មជូនអតិថិជន។

### ង. ស្ថានភាពទីផ្សារ

ទីផ្សាររថយន្តនៅកម្ពុជាសម្រាប់ឆ្នាំ ២០២៣ មានការធ្លាក់ចុះចំនួន -២៨% បើធៀបនឹងឆ្នាំមុន ដែលមានចំនួនប្រមាណ៥១.០០០គ្រឿង ទាំងរថយន្តថ្មី និងរថយន្តប្រើហើយ ដែលត្រូវបានលក់ និងចុះបញ្ជី ដែលមានចំនួនប្រមាណ ៧១,០០០គ្រឿង បើធៀបនឹងឆ្នាំ២០២២។ ការលក់រថយន្តថ្មីមានចំនួន ២៤,០០០ គ្រឿង ដែលបានធ្លាក់ចុះចំនួន -១៣% បើធៀបនឹងឆ្នាំ២០២២។ នៅក្នុងឆ្នាំ២០២៣ ទីផ្សាររថយន្តថ្មីបានកើនឡើង ៤៧% នៃទីផ្សារសរុប ដោយមានការឈានមុនពី ៣៩% នៅឆ្នាំ២០២២។ ។

### ច. សកម្មភាពប្រកួតប្រជែង

ការប្រកួតប្រជែងទីផ្សាររថយន្តនៅកម្ពុជាបានកើនឡើងនៅឆ្នាំ២០២៣ ជាមួយនឹងការមកដល់នៃម៉ាកថ្មីដែលសំខាន់មកពីប្រទេសចិន។ ទីផ្សារក៏បានលេចឡើងនូវបច្ចេកវិទ្យាថ្មីៗដូចជារថយន្តអគ្គិសនីជាដើម។

### ឆ. គ្រោងការណ៍អនាគត

ក្រុមហ៊ុននឹងខិតខំឱ្យក្លាយជាអ្នកផ្គត់ផ្គង់ឈានមុខគេនៃរថយន្ត សំណង់ គ្រឿងចក្រកសិកម្ម និងឧបករណ៍សម្រាប់លើកសម្ភារៈលំដាប់ពិភពលោកនៅកម្ពុជា។ តាមរយៈការនាំចូលនូវម៉ាកយីហោល្បីៗ គោលដៅរបស់ក្រុមហ៊ុនគឺធ្វើជាអ្នកផ្គត់ផ្គង់ឆ្ពោះមុខនៃផលិតផលនីមួយៗទាំងបីប្រភេទ ខណៈពេលដែលកំពុងផ្តល់សេវាកម្មលំដាប់ពិភពលោក ទៅលើសេវាកម្មក្រោយការលក់ និងសេវាកម្ម ព្រមទាំងធានានូវការគាំទ្រការធានាពេញលេញនៃផលិតផលដែលបានលក់។

ក្រុមហ៊ុនមានបំណងបន្តក្លាយជាអ្នកនាំមុខគេក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការវិនិយោគលើសម្ភារៈបរិក្ខារ និងមជ្ឈមណ្ឌលសេវាកម្មថ្មីៗ ពង្រឹងសមត្ថភាពឌីជីថល និងស្វែងរកឱកាសអាជីវកម្មថ្មីៗ ដើម្បីបង្កើនបទពិសោធន៍អតិថិជន និងបង្កើតតម្លៃសម្រាប់ម្ចាស់ភាគហ៊ុនរបស់យើង។

## ជ. កត្តាហានិភ័យ

ឧស្សាហកម្មយានយន្ត គ្រឿងចក្រកសិកម្ម និងគ្រឿងបរិក្ខារធុនធ្ងន់ជាទូទៅប្រឈមនឹងកត្តាហានិភ័យជាក់លាក់មួយចំនួន។ តាមទស្សនៈសាជីវកម្ម ឧស្សាហកម្មទាំងនេះពឹងផ្អែកលើការសមត្ថភាពរបស់អ្នកផ្គត់ផ្គង់ក្នុងការផ្គត់ផ្គង់ទាន់ពេលវេលា ប្រកបដោយគុណភាពដែលឆ្លុះបញ្ចាំងពីចំណូលចិត្តរបស់អតិថិជន។

ហានិភ័យដែលកើតឡើងពីអតិថិជនគឺចំណូលចិត្តដែលមានការផ្លាស់ប្តូរទៅតាមបរិបទសង្គម ដោយការផ្លាស់ប្តូរនេះទទួលបានការជះឥទ្ធិពលពីវប្បធម៌ និងបរិស្ថាន។

## ផ្នែកទី២.- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក. លទ្ធផលប្រតិបត្តិការធុរកិច្ច រាប់បញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

សមិទ្ធិផលសំខាន់ៗក្នុងឆ្នាំ២០២៣ រួមមាន៖

<u>ភាពឈានមុខគេក្នុងទីផ្សាររបស់រថយន្តម៉ាក Ford៖</u>

សម្រាប់ឆ្នាំ២០២៣ រថយន្តម៉ាក Ford នៅតែរក្សាភាពឈានមុខគេក្នុងទីផ្សារ។ រថយន្តម៉ាក Ford Ranger នៅតែបន្តជារថយន្តលំដាប់ទីមួយដែលលក់ដាច់ជាងគេក្នុងចំណោមទីផ្សាររថយន្តថ្មីក្នុងប្រទេសកម្ពុជា។

**<u>គ្រឿងចក្រម៉ាក John Deere៖</u>**

យោងតាមប្រភពផ្ទៃក្នុងរបស់យើង John Deere នៅជាអ្នកនាំមុខទី២នៅក្នុងទីផ្សារត្រាក់ទ័រក្នុងប្រទេសកម្ពុជា និងរក្សាតំណែងជាអ្នកនាំមុខលើត្រាក់ទ័រធន់ធំ និងម៉ាស៊ីនប្រមូលផលនៅកម្ពុជា។

**<u>លទ្ធផលហិរញ្ញវត្ថុ៖</u>**

ប្រាក់ចំណូលប្រចាំឆ្នាំ២០២៣ គឺចំនួន ១.៨០០ ប៊ីលលានរៀលដែលជាមានការថយចុះចំនួន -១៨,៣% បើប្រៀបធៀបទៅនឹងចំណូលឆ្នាំ២០២២។ ប្រាក់ចំណេញពីឆ្នាំ២០២៣ បន្ទាប់ពីការបង់ពន្ធមានចំនួន ១១៣,៧ ប៊ីលលានរៀល។

ក្រុមហ៊ុន RMAC បានធ្វើការវិនិយោគនូវសាច់ប្រាក់សុទ្ធចំនួន ១៩ ប៊ីលលានរៀលក្នុងរយៈពេល១២ខែនៃឆ្នាំ២០២៣ ដោយរាប់បញ្ចូលទាំងការសាងសង់អគារតាំងបង្ហាញថ្មី ការទិញរថយន្តថ្មី និងគ្រឿងបរិក្ខារបន្ថែមសម្រាប់ប្រតិបត្តិការផ្សេងៗ។

### ខ. រចនាសម្ព័ន្ធប្រាក់ចំណូល

ក្រុមហ៊ុន RMAC គឺជាក្រុមហ៊ុនដែលមានលក្ខណៈបែបចម្រុះ ដែលបានតំណាងអោយយីហោលំដាប់ពិភពលោកមួយចំនួនរួមមាន Ford, Land Rover, Changan, After-Sales Mercedes-Benz, Fuso, John Deere, JCB និង Piaggio។ ផលចំណូលរបស់ក្រុមហ៊ុនទាំងអស់ ត្រូវបានបែងចែកជាពីរប្រភេទ៖

- ការលក់ទំនិញ៖ ចំណូលទាក់ទងនឹងការលក់យានយន្ត និងបរិក្ខាផ្សេងៗ។
- ចំណូលពីសេវាកម្ម៖ ចំណូលទាក់ទងនឹងសេវាជួសជុល និងថែទាំយានយន្ត និងបរិក្ខា។

តារាងខាងក្រោមបង្ហាញពីចំណូលពីរប្រភេទសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២៣ និងការប្រៀបធៀបក្នុងរយៈពេលបីឆ្នាំចុងក្រោយ។

| គិតជាពាន់រៀល | ២០២៣ | ភាគរយ | ២០២២ | ភាគរយ | ២០២១ | ភាគរយ |
|---|---|---|---|---|---|---|
| ការលក់ទំនិញ | ១.៧២៩.៥៦៦.២០៥ | ៩៦,១% | ២.១៩១.៧០២.៨២៧ | ៩៧,២% | ១.៥៩១.៤៩០.៧៦៧ | ៩៧,៨% |
| ចំណូលនៃសេវាកម្ម | ៧០.៧៩៥.៨៨៩ | ៣,៩% | ៦១.៥៥០.៦២៦ | ២,៨% | ៣៥.០៤៩.២៥៧ | ២,២% |
| សរុប | ១.៨០០.៣៦២.០៩៤ | ១០០,០% | ២.២០៣.២៥៣.៤៥៣ | ១០០,០% | ១.៦២៦.៥៤០.០២៤ | ១០០,០% |

## ផ្នែកទី៣.- ព័ត៌មានស្តីអំពីអភិបាលកិច្ចរបស់ក្រុមហ៊ុន

### ក. រចនាសម្ព័ន្ធក្រុមហ៊ុន



## ខ. ក្រុមប្រឹក្សាភិបាល

សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះ | តំណែង | កាលបរិច្ឆេទតែងតាំង | កាលបរិច្ឆេទបញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | លោក Kevin Robert Whitcraft | ប្រធានក្រុមប្រឹក្សាភិបាល | ២៦ កញ្ញា ២០០២ | ២៨ កក្កដា ២០២៥ |
| ២ | លោក Thomas Arthur Whitcraft | អភិបាលមិនប្រតិបត្តិ | ២៦ កញ្ញា ២០០២ | ២៨ កក្កដា ២០២៥ |
| ៣ | លោក ងន សាំង | អភិបាលប្រតិបត្តិ និងជានាយកប្រតិបត្តិ | ២៣ មីនា ២០១៦ | ២៨ កក្កដា ២០២៥ |
| ៤ | លោក Ith Vichit | អភិបាលឯករាជ្យ | ២៩ កក្កដា ២០១៩ | ២៨ កក្កដា ២០២៥ |
| ៥ | លោក Wiedmann Apiwat Christian | អភិបាលមិនប្រតិបត្តិ | ៣១ ឧសភា ២០២៣ | ២៨ កក្កដា ២០២៥ |

លេខាធិការក្រុមហ៊ុន៖ លោក មាស សុវណ្ណ នាយកគ្រប់គ្រងផ្នែកច្បាប់ និងអនុលោមភាព។

## គ. មន្ត្រីជាន់ខ្ពស់

សមាសភាពមន្ត្រីជាន់ខ្ពស់

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ១ | លោក ងន សាំង | ប្រុស | នាយកប្រតិបត្តិ |
| ២ | លោក សេង រឹង | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែក Ford |
| ៣ | លោក Erwan Soubelet | ប្រុស | នាយកហិរញ្ញវត្ថុ |
| ៤ | កញ្ញា ហ៊ុំ សោភ័ណវតី | ស្រី | ប្រធានគ្រប់គ្រងទូទៅផ្នែក JLR |
| ៥ | លោក សុខ សុន្ទរ៉ា | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែកបរិក្ខារកសិកម្ម |
| ៦ | លោក តាន់ អាង | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែកប្រតិបត្តិនៃបរិក្ខារពិសេស |
| ៧ | លោក Grant Honeyman | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែកធនធានមនុស្ស |
| ៨ | លោក ឈឿន មករា | ប្រុស | ប្រធានផ្នែកភ័ស្តុភារ (Logistics) |
| ៩ | លោក មាស សុវណ្ណ | ប្រុស | លេខាធិការក្រុមហ៊ុន |
| ១០ | លោកស្រី ណាង ពិសី | ស្រី | ប្រធានផ្នែកទំនាក់ទំនងសាធារណៈ |
| ១១ | លោកស្រី សុខ ណារី | ស្រី | ប្រធានផ្នែកលទ្ធកម្ម |
| ១២ | លោក មុំ សុវណ្ណារ៉ា | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែកបរិក្ខារធនធ្ងន់ |
| ១៣ | លោក នូ ណារុណ | ប្រុស | ប្រធានគ្រប់គ្រងទូទៅ (ផ្នែកដែលត្រូវតំឡើង) |
| ១៤ | លោក សួស សុភា | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែក គ្រឿងបន្លាស់រថយន្ត (ថ្នាំលាបរថយន្ត និងអាគុយ) |
| ១៥ | លោក រិទ្ធ ច័ន្ទរតនៈ | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែក Changan |

| | | | |
|---|---|---|---|
| **១៦** | លោក កែវ សុវណ្ណរិទ្ធិ | ប្រុស | ប្រធានគ្រប់គ្រងទូទៅផ្នែក ឌីជីថល និងបច្ចេកវិទ្យាព័ត៌មាន |
| **១៧** | លោក Aung Htun | ប្រុស | ប្រធានផ្នែកគម្រោង |
| **១៨** | លោក សុខ ចន្ទ្រា | ប្រុស | ទីស្នាក់ការផ្នែកទំនាក់ទំនងអតិថិជន & បច្ចេកទេសក្នុងការប្រមូល និងស្តុកព័ត៌មានរបស់ក្រុមហ៊ុន (business intelligence) |
| **១៩** | លោក ផុន ឆោមឆវ៉ា | ប្រុស | អ្នកគ្រប់គ្រងបរិស្ថាន និងសង្គម |

សម្គាល់៖ ព័ត៌មានលម្អិតនៃអភិបាលកិច្ចក្រុមហ៊ុនត្រូវបានភ្ជាប់ដូចនៅក្នុងឧបសម្ព័ន្ធ។

## ផ្នែកទី៤. ព័ត៌មានស្តីអំពីការលក់ដមូលបត្រ និងម្ចាស់ភាគហ៊ុន

### ក. ព័ត៌មានស្តីពីមូលបត្រ

១. ព័ត៌មានស្តីពីមូលបត្រកម្មសិទ្ធិ (សម្រាប់ក្រុមហ៊ុនបោះផ្សាយកម្មសិទ្ធិ)

- ឈ្មោះមូលបត្រកម្មសិទ្ធិ [គ្មាន]
- និមិត្តសញ្ញានៃមូលបត្រកម្មសិទ្ធិ [គ្មាន]
- ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ [គ្មាន]
- តម្លៃក្នុងមួយមូលបត្រកម្មសិទ្ធិ [គ្មាន]
- តម្លៃ IPO [គ្មាន]
- ចំនួនសរុបនៃភាគហ៊ុនដែលនៅសល់ [គ្មាន]
- មូលធនទីផ្សារ [គ្មាន]
- ការអនុញ្ញាតឲ្យមានទីផ្សារមូលបត្រ [គ្មាន]

២. ព័ត៌មានស្តីពីមូលបត្របំណុល (សម្រាប់ក្រុមហ៊ុនបោះផ្សាយបំណុល)

| ព័ត៌មាន | ការពិពណ៌នា |
|---|---|
| **ប្រភេទនៃមូលបត្របំណុល** | សញ្ញាបណ្ណសាជីវកម្ម |
| **និមិត្តសញ្ញា** | សញ្ញាបណ្ណសាជីវកម្ម អ អិម អេ ខេមបូឌា ("សញ្ញាបណ្ណ") |
| **កាលបរិច្ឆេទបោះផ្សាយ** | ៩ មេសា ២០២០ |
| **ចំនួនសរុបនៃបំណុល** | ៨០ ពាន់លានរៀល (ឬ សមមូលជាប្រាក់ដុល្លាររហូតដល់ ២០ លានដុល្លារអាមេរិក ដោយយកចំនួនណាដែលតូចជាង) |
| **ចំនួនសរុបនៃមូលបត្របំណុលដែលនៅសល់** | មិនមាន |
| **ឥណប្រតិទាន** | ៥ ឆ្នាំ [២០២០-២០២៥] គិតចាប់ពីកាលបរិច្ឆេទបោះផ្សាយ |
| **កាលវិភាគបង់គូប៉ុង** | ត្រូវបង់ប្រចាំឆ្នាំនៅរៀងរាល់ថ្ងៃទី ០៩ ខែមេសា ឆ្នាំ.... |
| **អត្រាគូប៉ុង(%)** | ៥,៥% ក្នុងមួយឆ្នាំ |
| **ចំនួនសរុបនៃការបង់គូប៉ុង** | មិនមាន |
| **ចំណាត់ថ្នាក់លទ្ធភាពសង (ប្រសិនបើមាន)** | សញ្ញាបណ្ណត្រូវបានធានាដោយស្ថាប័ន CGIF។ យោងតាមប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ: មិនមានលក្ខខណ្ឌតម្រូវឱ្យធ្វើចំណាត់ថ្នាក់លទ្ធភាពសងលើសញ្ញាបណ្ណសាជីវកម្មដែលមានការធានានោះទេ ប៉ុន្តែបុគ្គលធានាតម្រូវឱ្យមានចំណាត់ថ្នាក់លទ្ធភាពសង។<br>ស្ថាប័ន CGIF មានលទ្ធភាពសងដូចតទៅ៖<br>- "AA/A-1+" កម្រិតសកល (រយៈពេលវែង និងរយៈពេលខ្លី) ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង Standard & Poor's នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ |

| | |
|---|---|
| | - "AAA" កម្រិតជាតិ ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង RMA Rating នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២៤<br>- "AAA" កម្រិតជាតិ ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង TRIS Rating ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣<br>- "AAA" កម្រិតជាតិ ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង Fitch Ratings នៃប្រទេសឥណ្ឌូនេស៊ី ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣<br>- "idAAA" កម្រិតជាតិ ទស្សនវិស័យស្ថេរភាព កំណត់ដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង Pefindo Credit Rating Agency ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ |

## ខ. តម្លៃមូលបត្រ និងបរិមាណនៃការលក់

| មូលបត្រ | | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| តម្លៃលក់ | អតិប្បរមា | [គ្មាន] | | | | | | | | | | | |
| | មធ្យម | [គ្មាន] | | | | | | | | | | | |
| | អប្បរមា | [គ្មាន] | | | | | | | | | | | |
| បរិមាណលក់ | អតិប្បរមា | [គ្មាន] | | | | | | | | | | | |
| | មធ្យម | [គ្មាន] | | | | | | | | | | | |
| | អប្បរមា | [គ្មាន] | | | | | | | | | | | |

## គ. ការគ្រប់គ្រងម្ចាស់ភាគហ៊ុន (៣០% ឬលើសពី៣០%)

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនភាគហ៊ុន | ចំនួនភាគរយ |
|---|---|---|---|---|
| ១ | Clipper Holding Ltd | ហុងកុង | ៩៩៩ | ៩៩,៩% |
| សរុប | | | ៩៩៩ | ៩៩,៩% |

## ផ្នែកទី៥ - របាយការណ៍សវនកម្មផ្ទៃក្នុងស្តីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក សម្រាប់ឆ្នាំ ២០២៣

### ១. សេចក្តីផ្តើម

មុខងារសវនកម្មផ្ទៃក្នុង គឺមានភាពឯករាជ្យពីផ្នែកគ្រប់គ្រងនិងប្រតិបត្តិការអាជីវកម្ម និងធ្វើរបាយការណ៍ផ្ទាល់ទៅគណៈកម្មាធិការសវនកម្មនិងហានិភ័យនៃក្រុមហ៊ុន។ ក្រុមសវនកម្មផ្ទៃក្នុងផ្តល់ជំនួយតាមតំបន និងគណៈគ្រប់គ្រងក្រុមហ៊ុនដោយអនុវត្តតាមវិធីសាស្រ្តដែលផ្អែកលើហានិភ័យដើម្បីវាយតម្លៃជាឯករាជ្យនូវប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុង និងនីតិវិធីគ្រប់គ្រងហានិភ័យ ភាពជឿជាក់លើព័ត៌មានដែលត្រូវបានប្រើសម្រាប់ការធ្វើរបាយការណ៍ និងការធ្វើសេចក្តីសម្រេចចិត្ត ការប្រើប្រាស់ធនធាន និងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនប្រកបដោយប្រសិទ្ធភាព និងការអនុលោមតាមស្តង់ដារសាជីវកម្ម ច្បាប់ គោលការណ៍អាជីវកម្មនិងអភិបាលកិច្ច។ មុខងារសវនកម្មផ្ទៃក្នុងត្រូវបានផ្តល់ជូនដោយ ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន អ អិម អេ ខេមបូឌា និង ក្រុមហ៊ុន អ អិម អេ គ្រុប ខូអិលធីឌី។

### ២. ទំនួលខុសត្រូវនៃតួនាទីសវនកម្មផ្ទៃក្នុង

តួនាទីសវនកម្មផ្ទៃក្នុងមានទំនួលខុសត្រូវដូចតទៅៈ

ក. ធ្វើរបាយការណ៍សវនកម្មផ្ទៃក្នុងទាំងអស់ និងផ្តល់របាយការណ៍ទាំងនេះទៅគណៈកម្មាធិការសវនកម្ម និងហានិភ័យ ដើម្បីពិនិត្យ វាយតម្លៃ និងបញ្ជូនទៅក្រុមប្រឹក្សាភិបាល

ខ. ផ្សព្វផ្សាយរាល់ការរកឃើញសំខាន់ៗដែលអាចជះឥទ្ធិពលដល់ប្រតិបត្តិការរបស់ក្រុមហ៊ុន អ អិម អេ ស៊ី ទៅកាន់គណៈកម្មាធិការសវនកម្ម និងហានិភ័យ ឬនាយកឯករាជ្យ។

គ. រៀបចំការប្រជុំជាមួយគណៈកម្មាធិការសវនកម្ម និងហានិភ័យយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ ដោយមិនមានវត្តមានថ្នាក់គ្រប់គ្រង

ឃ. អនុវត្តមុខងារផ្សេងៗទៀតដែលបានចាត់តាំងដោយ គណៈកម្មាធិការសវនកម្មនិងហានិភ័យ និង ក្រុមប្រឹក្សាភិបាល និង;

ង. មុខងារផ្សេងទៀតដែលកំណត់ដោយគណៈកម្មាធិការសវនកម្មនិងហានិភ័យ និងក្រុមប្រឹក្សាភិបាល។

### ៣. សកម្មភាពសវនកម្មផ្ទៃក្នុង ឆ្នាំ២០២៣

នៅក្នុងឆ្នាំ២០២៣ សវនកម្មផ្លូវការមួយក្រោមរូបភាពជាការតាមដាន (Follow Up) ត្រូវបានអនុវត្តដើម្បីវាយតម្លៃឡើងវិញនូវវឌ្ឍនភាពរបស់អាជីវកម្មក្នុងការអនុវត្តតាមអនុសាសន៍ពីសវនកម្មមុនៗទាំងអស់។ សវនកម្មនេះ បានរកឃើញថាមិនមានសកម្មភាពចំបងឬជាសារជាតុ (significant / material) ដែលខុសពីការរំពឹងទុកនោះទេ។ ក្រុមហ៊ុនសវនកម្មខាងក្រៅត្រូវបានចូលរួមដើម្បីជួយក្នុងការអនុវត្តកម្មវិធីសវនកម្ម ដែលត្រួតពិនិត្យដោយប្រធានសវនកម្មផ្ទៃក្នុង។

## ៩. សេចក្តីសន្និដ្ឋាន

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ធ្វើការវាយតម្លៃផ្អែកលើហានិភ័យប្រចាំឆ្នាំនៃអាជីវកម្មរបស់ក្រុមហ៊ុននិងគាំទ្រមុខងារ និងរាយការណ៍ការរកឃើញរបស់ខ្លួនទៅគណៈកម្មាធិការសវនកម្ម និងហានិភ័យ និងនាយកប្រតិបត្តិការគ្រប់គ្រង។ ចំណុចដែលមានហានិភ័យត្រូវបានគូសបញ្ជាក់ឱ្យបានឃើញ ហើយអនុសាសន៍ក៏ត្រូវបានចេញ ដែលទាមទារឱ្យមានការកែតម្រូវផែនការសកម្មភាពដោយគណៈគ្រប់គ្រងដើម្បីអនុវត្តអនុសាសន៍ទាំងនោះសម្រាប់ឆ្នាំ២០២៤។

**បានអាន និង អនុម័ត**
**កាលបរិច្ឆេទ: ១៩ មេសា ២០២៤**
**ហត្ថលេខា**



**ប្រធានសវនកម្ម និងហានិភ័យ**
**គណៈកម្មាធិការ**

**កាលបរិច្ឆេទ: ១៩ មេសា ២០២៤**
**ហត្ថលេខា**



**លោក Ngeng Kim**
**ជ.ប្រធានសវនកម្មផ្ទៃក្នុង**

## ផ្នែកទី៦ - របាយការណ៍ហិរញ្ញវត្ថុត្រួតពិនិត្យដោយសវនករផ្ទៃក្នុង

សូមយោងលើឧបសម្ព័ន្ធសម្រាប់ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលបានបញ្ចប់នៅ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣

## ផ្នែកទី៧ - ព័ត៌មានស្តីពីប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍

ក្រុមហ៊ុនបោះផ្សាយត្រូវបង្ហាញឯកសារព័ត៌មានស្តីពីប្រតិបត្តិការ ភាគីដែលពាក់ព័ន្ធនៅកំឡុងពេលពីរឆ្នាំចុងក្រោយ បញ្ជាក់ឈ្មោះ ទំនាក់ទំនងរវាងក្រុមហ៊ុនបោះផ្សាយ និងភាគីពាក់ព័ន្ធ ទំហំនៃប្រតិបត្តិការ និង ប្រភេទនៃការប្រាក់ដែលកើតចេញពីទំនាក់ទំនងដូចខាងក្រោម:

ក. ឯកសារប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុនដែលកាន់ភាគហ៊ុនយ៉ាងតិច៥% (ប្រាំភាគរយ) ឬច្រើននៃចំនួនមូលបត្រកម្មសិទ្ធិដែលនៅសល់

សូមមើលលើឧបសម្ព័ន្ធសម្រាប់ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ឆ្នាំហិរញ្ញវត្ថុឆ្នាំ ២០២៣ ចំនុច ២៧ "ភាគីពាក់ព័ន្ធ"

ខ. ឯកសារប្រតិបត្តិការជាមួយអភិបាល និងមន្ត្រីជាន់ខ្ពស់

សូមមើលលើឧបសម្ព័ន្ធសម្រាប់ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ឆ្នាំហិរញ្ញវត្ថុឆ្នាំ ២០២៣ ចំនុច ២៧"ភាគីពាក់ព័ន្ធ

គ. ប្រតិបត្តិការជាមួយអភិបាល និងម្ចាស់ភាគហ៊ុនពាក់ព័ន្ធដើម្បីទិញឬលក់ទ្រព្យសម្បត្តិ និងសេវាកម្ម

មិនមាន

ឃ. ឯកសារប្រតិបត្តិការជាមួយសមាជិកគ្រួសាររបស់អភិបាល មន្ត្រីជាន់ខ្ពស់ និងម្ចាស់ភាគហ៊ុនដែលកាន់ភាគហ៊ុនយ៉ាងតិច៥% (ប្រាំភាគរយ)ឬច្រើន

មិនមាន

ង. ឯកសារប្រតិបត្តិការជាមួយបុគ្គលដែលជាប់ទាក់ទងនឹងអភិបាលនៃក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនកាន់កាប់ដែលមានទំនាក់ទំនងនៅក្នុងប្រតិបត្តិការណាមួយ ឬបានធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយ

មិនមាន

ច. ឯកសារប្រតិបត្តិការជាមួយអតីតអភិបាល ឬបុគ្គលដែលបានចូលរួមជាមួយអតីតអភិបាល

មិនមាន

ឆ. ឯកសារប្រតិបត្តិការជាមួយអភិបាលដែលកំពុងកាន់តំណែងនៅក្នុងអង្គការគ្មានប្រាក់ចំណូល ឬនៅក្នុងក្រុមហ៊ុនផ្សេងៗទៀតក្រៅពីក្រុមហ៊ុនបោះផ្សាយ

មិនមាន

ជ. ឯកសារប្រតិបត្តិការជាមួយនាយកដែលទទួលបានចំនូល ឬមិនបានចំណូលពីក្រុមហ៊ុនបោះផ្សាយ

សូមមើលលើឧបសម្ព័ន្ធសម្រាប់ព័ត៌មានហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់ឆ្នាំហិរញ្ញវត្ថុឆ្នាំ ២០២៣ ចំនុច ២៧ "ភាគីពាក់ព័ន្ធ

សម្រាប់គោលបំណងនៃការបង្ហាញ កម្រិតតម្លៃនៃប្រតិបត្តិការសម្ភារៈត្រូវបានកំណត់ចំនួន USD ១០០.០០០

## ផ្នែកទី៨ - ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

១. ការវិភាគចំណូល

ចំណូលសរុប មានចំនួន ១.៨០០ ប៊ីលលានរៀល ក្នុងឆ្នាំ២០២៣ ដែលបានថយចុះចំនួន -៤០២,៩ ប៊ីលលានរៀល ឬ -១៨,៣% នៅក្នុងឆ្នាំ២០២៣ បើធៀបទៅនឹងឆ្នាំ២០២២។

២. ផ្នែកនៃចំណូល

ប្រាក់ចំណូលនៅឆ្នាំ២០២៣ បានធ្លាក់ចុះ លើផ្នែករបស់ Ford វិស័យកសិកម្ម និង ផលិតផលបរិក្ខារពិសេស បើប្រៀបធៀបទៅនឹងឆ្នាំមុន ខណៈដែលក្រុមហ៊ុន Land Rover, Changan, គ្រឿងចក្រធុនធ្ងន់ (Heavy-Equipment) និង Piaggio បានកើនឡើងនៃការលក់ខ្លាំងជាងឆ្នាំមុន។

៣. គម្លាតចំណេញដុល

| គិតជាពាន់រៀល | ២០២៣ | ២០២២ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| **ចំណូលសរុប** | ១.៨០០.៣៦២.០៩៤ | ២.២០៣.២៥៣.៤៥៣ | (៤០២.៨៩១.៣៥៩) | -១៨,៣% |
| **ចំណេញដុល** | ៣១២.៩៣០.៦៥៨ | ៤១៧.៩៩៨.២១៩ | (១០៥.០៦៧.៥៦១) | -២៥,១% |
| **គម្លាតចំណេញដុល** | *១៧,៤%* | *១៩,០%* | | |

៤. ការវិភាគអំពីប្រាក់ចំណេញមុនបង់ពន្ធ (PBT)

| គិតជាពាន់រៀល | ២០២៣ | ២០២២ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| **ចំណូលសរុប** | ១.៨០០.៣៦២.០៩៤ | ២.២០៣.២៥៣.៤៥៣ | (៤០២.៨៩១.៣៥៩) | -១៨,៣% |
| **ចំណេញដុល** | ៣១២.៩៣០.៦៥៨ | ៤១៧.៩៩៨.២១៩ | (១០៥.០៦៧.៥៦១) | -២៥,១% |
| **គម្លាតចំណេញដុល** | *១៧,៤%* | *១៩,០%* | | |
| **ចំណាយ** | ១៩៤.០៩៧.៩០៧ | ១០៩.១៣៧.៣៦៣ | ៣៤.៩៦០.៥៤៤ | *៣២,០%* |
| **ចំណាយហិរញ្ញវត្ថុ** | ២៩.៤១២.៤៥១ | ១២.៨០១.៩៤៣ | ១៦.៦១០.៥០៨ | *១២៩,៧%* |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | ១៣៩.៤២០.៣០០ | ២៩៦.០៥៨.៩១៣ | (១៥៦.៦៣៨.៦១៣) | -៥២,៩% |
| **គម្លាត** | *៧,៧%* | *១៣,៤%* | | |

៥. ការវិភាគអំពីប្រាក់ចំណេញក្រោយបង់ពន្ធ (PAT)

| គិតជាពាន់រៀល | ២០២៣ | ២០២២ | ចំនួនប្រែប្រួល | ភាគរយនៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| **ប្រាក់ចំណេញមុនបង់ពន្ធ** | ១៣៩,៤២០,៣០០ | ២៩៦.០៥៨.៩១៣ | (១៥៦.៦៣៨.៦១៣) | -៥២,៩% |
| **ចំណាយពន្ធ** | ២៥,៦៩៧,១៦៧ | ៥២.៤៩៣.៣៨៣ | (២៦.៧៩៦.២១៦) | -៥១,០% |
| **ប្រាក់ចំណេញក្រោយបង់ពន្ធ** | ១១៣,៧២៣,១៣៣ | ២៤៣.៥៦៥.៥៣០ | (១២៩.៨៤២.៣៩៧) | -៥៣,៣% |
| **គម្លាតប្រាក់ចំណេញក្រោយបង់ពន្ធ** | *៦,៣%* | *១១,១%* | | |

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញ

១. ការវិភាគអំពីតម្រូវការ និង ការផ្គត់ផ្គង់

អតិថិជនរបស់ RMAC នៅក្នុងប្រទេសកម្ពុជា បង្ហាញពីចំណាប់អារម្មណ៍លើការទិញម៉ាកយីហោសំខាន់ៗរបស់ RMAC ដូចជា Ford, Changan, John Deere និង Land Rover។

RMAC បានធ្វើការតាមដានយ៉ាងជិតដល់នូវប្រភពបំពង់បង្ហូរប្រេង(sourcing pipeline) សម្រាប់ផ្នែកនីមួយៗដើម្បីធ្វើការសម្រេចចិត្តសមស្របទាក់ទងនិងការបញ្ជាទិញ។

២. ការវិភាគអំពីការប្រែប្រួលនូវតម្លៃវត្ថុធាតុដើម

មិនមានការប្រែប្រួលសំខាន់លើតម្លៃនៃវត្ថុធាតុដើមឡើយ។

៣. ការវិភាគអំពីពន្ធដារ

ថ្មីៗនេះមិនមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅក្នុងបទប្បញ្ញត្តិពន្ធនៅក្នុងប្រទេសកម្ពុជាដែលមានឥទ្ធិពលប៉ះពាល់ទៅលើដំណើរការហិរញ្ញវត្ថុរបស់យើងទេ។

៤. ការវិភាគអំពីទំនិញលើកលែង និងទំនិញពិសេស

មិនមានទំនិញលើកលែង និងទំនិញពិសេសក្នុងអំឡុងពេលនេះឡើយ។

## គ. ការផ្លាស់ប្តូរសំខាន់ៗពាក់ព័ន្ធនឹងការលក់ និងចំណូល

ចំណូលសម្រាប់ឆ្នាំ២០២៣ នឹងត្រូវប្រៀបធៀបជាមួយនឹងឆ្នាំ២០២២ គឺនឹងត្រូវបង្ហាញក្នុងឯកសារនេះ និងនៅក្នុងរបាយការណ៍សវនកម្មហិរញ្ញវត្ថុសង្ខេបដែលបានបញ្ចប់នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣។

## ឃ. ផលប៉ះពាល់នៃអត្រាប្តូរប្រាក់ អត្រាការប្រាក់ និងតម្លៃទំនិញ

ការប្រែប្រួលអត្រាប្តូរប្រាក់ មិនមានការប៉ះពាល់ចំបងណាមួយដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ ដោយហេតុថាអាជីវកម្មមួយចំនួនធំរបស់ក្រុមហ៊ុនត្រូវបានធ្វើឡើងជាប្រាក់រៀល/ប្រាក់ដុល្លារអាមេរិកភ្ជាប់ជាមួយនឹងការបញ្ជាទិញនូវផលិតផលនាំចូលតិចតួចប៉ុណ្ណោះដែលធ្វើឡើងជារូបិយបណ្ណបរទេស។ ក្រុមហ៊ុនមិនបានទទួលរងផលប៉ះពាល់ដោយតម្លៃទំនិញ ដោយសារក្រុមហ៊ុនមិនបានធ្វើការដោះដូរទំនិញឡើយ។ អត្រាការប្រាក់ មានការប្រែប្រួលបន្តិចបន្តួចតែប៉ុណ្ណោះក្នុងអំឡុងពេលនេះ។

## ង. ផលប៉ះពាល់នៃអតិផរណា

មិនមានផលប៉ះពាល់ចំបងណាមួយនៃអតិផរណា ដែលបានប៉ះពាល់ដល់ដំណើរការផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

មិនមានផលប៉ះពាល់ចំបងណាមួយដែលបណ្តាលមកពីការប្រែប្រួលនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលនាំឱ្យមានការជះឥទ្ធិពលដល់អាជីវកម្មរបស់យើងឡើយ។

## ឆ. ព្រឹត្តិការណ៍សំខាន់ៗ

មិនមានព្រឹត្តិការណ៍សំខាន់ផ្សេងទៀតទេ។

## ហត្ថលេខារបស់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ

កាលបរិច្ឆេទ៖ ១៩ មេសា ២០២៤

បានអាន និង អនុម័តដោយ:

.........................................

ហត្ថលេខា

ឈ្មោះ៖ លោក Kevin Whitcraft

តំណែង៖ ប្រធានក្រុមប្រឹក្សាភិបាល

បានអាន និង អនុម័តដោយ:

.........................................

ហត្ថលេខា

ឈ្មោះ៖ លោក Thomas Arthur Whitcraft

តំណែង៖ អភិបាលមិនប្រតិបត្តិ

បានអាន និង អនុម័តដោយ:

.........................................

ហត្ថលេខា

ឈ្មោះ៖ លោក **ឯន សាំង**

តំណែង៖ អភិបាលប្រតិបត្តិ និងជានាយកប្រតិបត្តិ

បានអាន និង អនុម័តដោយ:

.........................................

ហត្ថលេខា

ឈ្មោះ៖ លោក Wiedmann Apiwat Christian

តំណែង៖ អភិបាលមិនប្រតិបត្តិ

បានអាន និង អនុម័តដោយ:

.........................................

ហត្ថលេខា

ឈ្មោះ៖ លោក Vichit Ith

តំណែង៖ អភិបាលឯករាជ្យ

RMA CAMBODIA

ដើម្បីក្លាយជាដៃគូដែលជាទីទុកចិត្តបំផុត និងយូរ
អង្វែង សម្រាប់ការអភិវឌ្ឍន៍ និងវិបុលភាព នៅកម្ពុជា

